គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៣៤ ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២
No. 34 Released on February 21, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# សមិទ្ធផលគន្លឹះសំខាន់ៗក្នុងវិស័យបរធនបាលកិច្ចមុនការបង្កើតនិយ័តករបរធនបាលកិច្ច

# Key Achievements in Trust Sector Before the Establishment of the Trust Regulator

ក្នុងក្របខណ្ឌនៃការគ្រប់គ្រងវិស័យបរធនបាលកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមាននាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ បានផ្តល់ការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុដែលទទួលមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុលក្នុងគោលបំណងអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុចំនួន ៩ អនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ និងអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣។

ក្រោមក្របខណ្ឌច្បាប់ស្តីពីបរធនបាលកិច្ច ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ និងអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ បានផ្តល់វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចចំនួន ៨ ដែលក្នុងនោះមានបរធនបាលកិច្ចពាណិជ្ជកម្មចំនួន ៤, បរធនបាលកិច្ចសាធារណៈចំនួន ១ និងបរធនបាលកិច្ចបុគ្គលចំនួន ៣ ជាមួយនឹងទំហំបរធនចំនួនសរុបប្រមាណ ១០១ លានដុល្លារអាមេរិក ដោយមិនរាប់បញ្ចូលបរធនបាលកិច្ចហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ក្នុងការអនុវត្តមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាបញ្ញត្តិករបរធនបាលកិច្ច នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការបានរៀបចំបទប្បញ្ញត្តិគាំទ្រមួយចំនួនបន្ថែមទៀតដែលក្នុងនោះមាន ប្រកាសស្តីពីការគ្រប់គ្រងនិងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ និងប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ចនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩។

Within the framework of management of the Ministry of Economy and Finance, with the Department of Market and Financial Institutions of the General Department of Financial Industry as the assistant, provided registration of the financial trusts, which received grants or sub-debt for development purposes for 9 banking and microfinance sectors in accordance with the Law on Financial Management for the year 2013, which was promulgated on December 26, 2012 and the Sub-Decree on Financial Trust, which was promulgated on August 26, 2013.

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

Under the framework of the Law on Trust, which was promulgated on January 2, 2019, and the Sub-Decree on Registration of Trust, which was promulgated on August 2, 2019, issued the Certificate of Registration for 8 trusts, including 4 commercial trusts, 1 public trust and 3 personal trusts with a total trust fund of 101 million US dollars, excluding financial trusts. At the same time, in carrying out the duties of the assistant of the Ministry of Economy and Finance, which was the regulator of trust sector at that time, the Department of Market and Financial Institution of the General Department of Financial Industry, had prepared a number of additional supporting regulations, including the Prakas on Management and Supervision of Financial Trust, which was promulgated on September 26, 2014 and the Prakas on Trust Registration Fee, which was promulgated on September 30, 2019.

អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.